សាលាដំបូងរាជធានីភ្នំពេញ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមចាត់រះបៀប**

-លេខ ៩៥ "ខ"ក្រ១០

-ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤២៩៨

ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ ៣៨៩៥

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ៣១៧៨

ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសាលសវនាការទី១ ដោយមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### ១.ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤២៩៨ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ដែលមាន**ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី៖**

១.១-ឈ្មោះ [redacted] **សុផេង** ភេទប្រុស កើតថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៩ ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តកំពង់ស្ពឺ។

ជាប់ចោទពីបទ: **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅមន្ទីរពេទ្យមិត្តភាព-សូវៀត សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៣៩នៃក្រមព្រហ្មទណ្ឌ។

១.២-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផេង**។

១.៣-ឈ្មោះ [redacted]**លាង** ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨០ ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកំពង់ស្ពឺ។

ជាប់ចោទពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសធ្ងន់ទោសនិងជនរងគ្រោះ** ប្រព្រឹត្តនៅភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២១៩ នៃក្រមព្រហ្មទណ្ឌ។

១.៤-ជនរងគ្រោះឈ្មោះ[redacted]**សារឿន** ភេទស្រី អាយុ៣៦ឆ្នាំ ទីកន្លែងកំណើតភូមិព្រៃកទឹទុយ ឃុំអង្គយាម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅភូមិព្រៃកទឹទុយ ឃុំយាមអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

១.៥-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះឈ្មោះ [redacted] **សារឿន**។



Scanned with CamScanner

## ២-អង្គហេតុនៃរឿងមានដូចតទៅ

២.១-**សារូបអង្គហេតុ៖** កាលពីអំឡុងខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] សារឿន បានសម្រាកព្យាបាលនៅមន្ទីរពេទ្យខ្មែរ-សូវៀត ហើយឈ្មោះ [redacted] សុផេង បានទៅមើលថែឈ្មោះ [redacted] សារឿន លុះនៅវេលាម៉ោងប្រហែល០៤ ពេលនោះមានសភាពស្ងប់ស្ងាត់ឈ្មោះ ម៉ែន សុផេង បានឆ្លៀតឱកាសចាប់រំលោភឈ្មោះ [redacted] សារឿន រហូតបានសម្រេច ហើយឈ្មោះ [redacted] សុផេង បានយកដៃខ្ទប់មាត់ឈ្មោះ [redacted] សារឿន មិនឱ្យស្រែក ណាមួយឈ្មោះ [redacted] សារឿន ដោយសារដៃស្តាំនិងដៃឆ្វេង ត្រូវបានបាក់ទើបធ្វើឱ្យរើចេញពីសកម្មភាពរបស់ឈ្មោះ [redacted] សុផេង មិនរួច។ បន្ទាប់ពីសកម្មភាព បានលួងលោមឈ្មោះ [redacted] សារឿន កុំឱ្យប្តឹង ដោយឈ្មោះ [redacted] សុផេង បានសន្យានឹងធានាខុសត្រូវ ទើបឈ្មោះ [redacted] សារឿន មិនបានដាក់ពាក្យបណ្តឹងភ្លាមៗ តែក្រោយមកឈ្មោះ [redacted] សុផេង មិនបានធ្វើតាមអ្វីដែលបានសន្យាថានឹងទទួលខុសត្រូវលើឈ្មោះ [redacted] សារឿន ឡើយ។ ហើយឈ្មោះ [redacted] សារឿន ក៏បានដាក់ពាក្យបណ្តឹងប្តឹងតែម្តង។

ក្រោយមកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ឈ្មោះ [redacted] សារឿន បានទៅសួរនាំពីរឿងរថយន្តរបស់ខ្លួនខូច ហើយជាងបានប្រាប់ថាឈ្មោះ សំអឿន បានធ្វើឱ្យខូច ស្រាប់តែឈ្មោះ សំបូរ ណាង បានមកសួរនាំថាមានបញ្ហាអី ហើយឈ្មោះ [redacted] សារឿន បានឆ្លើយថាបញ្ហារឿងខូចឡាន ស្រាប់តែឈ្មោះ [redacted] ណាង បានយកឈើច្រត់មកវាយលើឈ្មោះ [redacted] សារឿន ត្រូវជាច្រើនកន្លែង ពេលនោះឈ្មោះ [redacted] សុផេង បានមកដល់ក៏បានចូលមកវាយឈ្មោះ [redacted] សារឿន បន្ថែមទៀត បណ្តាលឱ្យឈ្មោះ [redacted] សារឿន បានរលូតកូន។ ដោយសារមូលហេតុខាងលើនេះទើបឈ្មោះ [redacted] សារឿន បានដាក់ពាក្យបណ្តឹងប្តឹង ឈ្មោះ [redacted] សុផេង និងឈ្មោះ [redacted] ណាង មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញតែម្តង។

២.២-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សារឿន។

២.៣-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៧៩៥ អ.យ.ក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.៤-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៩៧២ អ.យ.ក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.៥-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣៨៣១ “ខ”ដ.ស ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## ៣-នាពេលសវនាការ

៣.១- ជនជាប់ចោទឈ្មោះ [redacted] **សុផេង៖** អវត្តមាន។

៣.២- ជនជាប់ចោទឈ្មោះ [redacted] **ណាង៖** អវត្តមាន។

៣.៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារឿន** បានឆ្លើយថា នៅអំឡុងខែកក្កដា ឆ្នាំ២០២១ ខ្លួនឈឺនិងបានស្នាក់នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ហើយឈ្មោះ [redacted] សុផេង ជាអ្នកមើលថែខ្លួន ហើយឈ្មោះ [redacted] សុផេង ក៏បានឆ្លៀតឱកាសរំលោភខ្លួន គាត់ក៏បានសន្យាថានឹងទទួលខុសត្រូវលើទង្វើដែលបានប្រព្រឹត្តមកលើខ្លួន ទើបខ្លួនមិនដាក់ពាក្យបណ្តឹង តែក្រោយមកឈ្មោះ [redacted] សុផេង ចេះតែប្រើអំពើហិង្សាមកលើខ្លួនជាបន្តបន្ទាប់ រហូតដល់ថ្ងៃទី១៧ ដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ បានលួចទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់ខ្លួនមានដូចជា មាស០៣តម្លឹង ០៨ជី, ទឹកប្រាក់ ចំនួន ៧៥០០ (ប្រាំពីរប្រាំរយ) ដុល្លារអាមេរិក, រថយន្ត,ម៉ូតូ, ប័ណ្ណសម្គាល់រថយន្ត,ប័ណ្ណសម្គាល់ ម៉ូតូ និងឯកសារទិញលក់រថយន្តនិងជួលរថយន្តទៅបាត់។ ហើយនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ឈ្មោះ [redacted] សុផេង ក៏បានជូនខ្លួនទៅមន្ទីរ



Scanned with CamScanner

ពេទ្យដើម្បីពិនិត្យផ្ទៃពោះ នៅពេលពិនិត្យរួចរាល់ហើយឈ្មោះ[redacted] សុផេង ក៏បានប្រាប់ថា ត្រូវទៅធ្វើរបងឱ្យគេ ហើយខ្លួនក៏បានជិះម៉ូតូម្នាក់ឯងមកកន្លែងធ្វើឡានមួយស្ថិតនៅភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីមកយកទុយោខ្យល់ នៅពេលទៅដល់ទីនោះខ្លួនក៏បានឃើញឡានរបស់ខ្លួនខូចក៏បានសួរនាំជាងឡានថា ឡានរបស់ខ្លួនខូចអ្វី ជាងឡានប្រាប់ថាជាស្ត្រីទន់ខ្សោយកំពុងមានផ្ទៃពោះ និងជាជនពិការរហូតដល់បាក់ឈើច្រត់ ស្រប ពេលនោះឈ្មោះ[redacted] លាង ក៏បានលួចយកទូរស័ព្ទរបស់ខ្លួន នៅក្នុងកាបូបដែលនៅក្នុងនោះ មានទឹកប្រាក់នៅក្នុងស្រោមទូរស័ព្ទ ចំនួន ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក និងទឹកប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល នៅពេលនោះឈ្មោះ[redacted] សុផេង ក៏បានមកវាយក្បាលខ្លួនបន្ថែមទៀត ដែលធ្វើឱ្យខ្លួនធ្លាក់ឈាមតាមទ្វារមាសរហូតមិនឈប់ ទើបខ្លួនដាក់ពាក្យបណ្តឹង។ សព្វថ្ងៃឈ្មោះ[redacted] សុផេង និងឈ្មោះ[redacted] លាង ស្នាក់នៅភូមិរលាំងបែង ឃុំយារង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ខ្លួនត្រឡប់មកផ្ទះវិញ ដោយឈ្មោះ[redacted] សុផេង ជាអ្នកមើលថែ។ មួយថ្ងៃក្រោយមក នៅវេលាម៉ោងប្រហែល០៤ រសៀល ស្រាប់តែឈ្មោះ[redacted] សុផេង បានធ្វើសកម្មភាព យកដៃខ្ទប់មាត់ខ្លួន ហើយយកដៃម្ខាង ស្រាតខោខ្លួនគាត់ និងស្រាតសារ៉ុងខ្លួន ហើយបានធ្វើសកម្មភាពចាប់រំលោភខ្លួនតែម្តង ដោយពេលនោះខ្លួនស្លៀកសារ៉ុង និងអាវដៃខ្លី ដោយមិនមានស្លៀកខោអាវក្នុងទេ។ គាត់ចាប់រំលោភខ្លួន ប្រហែលបីនាទីទើបចេញទឹកកាមក្នុងប្រដាប់ភេទរបស់ខ្លួន ហើយបានដកប្រដាប់ភេទគាត់ចេញវិញ ដោយយកកន្សែងមកជូតប្រដាប់ភេទគាត់ ប្រដាប់ភេទខ្លួន និងគ្រែពេទ្យ ហើយក៏បានយកទូរស័ព្ទថតប្រដាប់ភេទរបស់ខ្លួន។ មូលហេតុ ដែលខ្លួនមិនបានដាក់ពាក្យបណ្តឹង ដោយសារឈ្មោះ[redacted] សុផេង បានខ្ទប់មាត់ខ្លួនមិនឱ្យស្រែក ហើយដោយសារ តែ ដៃស្តាំ និងជើងឆ្វេង ខ្លួនសុទ្ធតែបាក់ទើបខ្លួនមិនអាចរើចេញពីសកម្មភាពរបស់គាត់បាន។ ពេលធ្វើសកម្មភាពរួច ឈ្មោះ[redacted] សុផេង បាននិយាយលួងលោមខ្លួន ថាកុំឱ្យប្តឹង គាត់នឹងទទួលខុសត្រូវចំពោះអំពើរបស់គាត់។ ដោយសារតែខ្លាចគាត់។ ដោយសារតែខ្លាចគាត់យករូបថតរបស់ខ្លួនទៅបង្ហោះ និងដោយសារគាត់ធានាថានឹងទទួលខុសត្រូវទើបខ្លួនមិនបានប្តឹងភ្លាមៗ។លុះចេញពីមន្ទីរពេទ្យគាត់បានជូនខ្លួនទៅផ្ទះ និងជូនខ្លួនទៅពិនិត្យនៅមន្ទីរពេទ្យជាប្រចាំ។ ពេលគាត់រំលោភខ្លួន គាត់ក៏បានធ្វើឱ្យខ្លួនមានផ្ទៃពោះផងដែរ ប៉ុន្តែកូននោះត្រូវបានរលូត ដោយសារតែខ្លួនដួល។ លុះអំឡុងឆ្នាំ២០២២ ស្រាប់តែឈ្មោះ[redacted] សុផេង បានលួចយកខ្សែកមាស ០៣តម្លឹង ០៨ជី, ទឹកប្រាក់ ចំនួន ៧៥០០ (ប្រាំពីរប្រាំរយ) ដុល្លារអាមេរិក, រថយន្ត,ម៉ូតូ,ប័ណ្ណសម្គាល់រថយន្ត ប័ណ្ណសម្គាល់ម៉ូតូ និងឯកសារទិញលក់រថយន្តនិងជួលរថយន្តទៅបាត់។ ខ្លួនក៏បានទំនាក់ទំនងទៅឈ្មោះ[redacted] សុផេង ដើម្បីយករបស់របរមកសងខ្លួនវិញ ប៉ុន្តែឈ្មោះ ម៉ែន សុផេង មិនបានដោះស្រាយឡើយ។ សូមមេត្តាជួយរកយុត្តិធម៌ និងផ្តន្ទាទោសឈ្មោះ[redacted] សុផេង និងឈ្មោះ[redacted] លាង ឱ្យបានត្រឹមត្រូវតាមច្បាប់។ សុំទាមទារប្រាក់ចំនួន ៨.៥៥០ (ប្រាំបីពាន់ប្រាំរយហាសិប) និងប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួនមកវិញរួមមានមាស០៣តម្លឹង ០៨ជី, ទឹកប្រាក់ ចំនួន ៧៥០០ (ប្រាំពីរប្រាំរយ) ដុល្លារអាមេរិក, រថយន្ត,ម៉ូតូ,ប័ណ្ណសម្គាល់រថយន្ត,ប័ណ្ណសម្គាល់ម៉ូតូ និងឯកសារទិញលក់រថយន្តនិងជួលរថយន្តទៅបាត់។ សុំទាមទារសំណងជម្ងឺចិត្តថ្លៃព្យាបាលចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

៣.៩-មេធាវី[redacted] បានសន្និដ្ឋានថា: សេចក្តីដូចបានបញ្ជាក់ក្នុងអង្គហេតុ និងអង្គច្បាប់ខាងលើឃើញថា គឺពិតជាមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដើម្បីចោទប្រកាន់មកលើឈ្មោះ[redacted] **សុផេង** ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចមន្ទីរពេទ្យមិត្តភាព-សូវៀត សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២១ តាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ[redacted] លាង ពីបទ **ហិង្សាដោយចេតនាមានស្ថាន**



Scanned with CamScanner

**ទម្លន់ទោសទាក់ទងនឹងជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ តាមមាត្រា ២១៩ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន។

ហេតុនេះ យើងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារឿន** សូមសំណូមពរលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រេចដូចខាងក្រោម៖

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សុរេង** និងឈ្មោះ [redacted] **ណាង** កម្រិតអតិបរមានៃទោស។

២.បង្គាប់ឱ្យឈ្មោះ [redacted] **សុរេង** និងឈ្មោះ [redacted] **ណាង** សងថ្លៃសម្ភារៈដែលបាត់បង់រួមមាន៖ ខ្សែកមា សទម្ងន់ ៣ តម្លឹង ៨ជី, ទឹកប្រាក់ ៧៨៥០ដុល្លារអាមេរិក, រថយន្ត ១គ្រឿង, ម៉ូតូ ១គ្រឿង ម៉ាក Suzuki Nex ពាក់ផ្លាកលេខ កំពង់ស្ពឺ 1I-5616, ប័ណ្ណសម្គាល់រថយន្ត, ប័ណ្ណសម្គាល់ម៉ូតូ, ឯកសារទិញលក់ និងជួលរថយន្ត, និងទូរស័ព្ទ មួយគ្រឿង ដែលមានតម្លៃសរុបចំនួន **៣១.៦៧០ (បីម៉ឺនមួយពាន់ប្រាំមួយរយចិតសិប) ដុល្លារអាមេរិក** ឱ្យមកដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារឿន** ។

៣. ដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] **សុរេង** និងឈ្មោះ [redacted] **ណាង** តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤. បង្គាប់ឱ្យឈ្មោះ [redacted] **សុរេង** និងឈ្មោះ [redacted] **ណាង** សងសំណងជម្ងឺចិត្ត និងថ្លៃព្យាបាលរបួស ចំនួន **៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក** ឱ្យមកកូនក្ដីខ្ញុំឈ្មោះ [redacted] **សារឿន**។

## សេចក្ដីសន្និដ្ឋានម្ដងសុំរបស់តំណាងអយ្យការ

៣.៩-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដីកាសន្និដ្ឋានស្ថាពរ សុំឱ្យលើកលែងចោទជនជាប់ចោទទាំងពីរ តាមដីកាដំណោះស្រាយធ្វើការបញ្ជូនជនជាប់ចោទទាំងពីរ ទៅជំនុំជម្រះ ស្នើសុំឱ្យពិនិត្យនិងសម្រេចតាមច្បាប់ ដោយគ្មានិសិទ្ធិ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

៣.១០-មេធាវី [redacted] បានសន្និដ្ឋានថា: ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឃើញថាមានវិមតិសង្ស័យ ស្របតាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានជាប្រយោជន៍ជនជាប់ចោទ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

៣.១១-ជនជាប់ចោទឈ្មោះ [redacted] **សុរេង** និងជនជាប់ចោទឈ្មោះ [redacted] **ណាង** បាននិយាយសំដីចុងក្រោយបង្អស់ថា៖ អវត្តមាន។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងសំណូមពរ។

-ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី និងសំណូមពរ ។

-ក្រោយពីបានស្ដាប់អំណានរបាយការណ៍។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យ ពិចារណា តាមច្បាប់ហើយ សាលាដំបូងរាជធានីភ្នំពេញ

## សំអាងហេតុ

៣.១- ជនជាប់ចោទឈ្មោះ [redacted] **សុរេង**៖ អវត្តមាន។

៣.២- ជនជាប់ចោទឈ្មោះ [redacted] **ណាង**៖ អវត្តមាន។



Scanned with CamScanner

៣.៣- តាមអំណានចម្លើយនៅដំណាក់កាលអយ្យការ និងនៅដំណាក់កាលចៅក្រមស៊ើបសួរព្រមទាំងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន នាពេលសវនាការបានឆ្លើយថា នៅអំឡុងខែកក្កដា ឆ្នាំ២០២១ ខ្លួនឈឺនិងបានស្នាក់នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ហើយឈ្មោះ [redacted] សុផេង ជាអ្នកមើលថែខ្លួន ហើយឈ្មោះ [redacted] សុផេង ក៏បានឆ្លៀតឱកាសរំលោភខ្លួន គាត់ក៏បានសន្យាថានឹងទទួលខុសត្រូវលើទង្វើដែលបានប្រព្រឹត្តមកលើខ្លួន ទើបខ្លួនមិនដាក់ពាក្យបណ្តឹង តែក្រោយមកឈ្មោះ [redacted] សុផេង ចេះតែប្រើអំពើហិង្សាមកលើខ្លួនជាបន្តបន្ទាប់ រហូតដល់ថ្ងៃទី១៧ ដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ បានលួចទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់ខ្លួនមានដូចជា មាស០៣តម្លឹង ០៨ជី, ទឹកប្រាក់ ចំនួន ៧៥០០ (ប្រាំពីរប្រាំរយ) ដុល្លារអាមេរិក, រថយន្ត,ម៉ូតូ,ប័ណ្ណសម្គាល់រថយន្ត,ប័ណ្ណសម្គាល់ ម៉ូតូ និងឯកសារទិញលក់រថយន្តនិងជួលរថយន្តទៅបាត់។

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ឈ្មោះ [redacted] សុផេង ក៏បានជូនខ្លួនទៅមន្ទីរពេទ្យដើម្បីពិនិត្យផ្ទៃពោះ នៅពេលពិនិត្យរួចរាល់ហើយឈ្មោះ [redacted] សុផេង ក៏បានប្រាប់ថា ត្រូវទៅធ្វើរបងឱ្យគេ ហើយខ្លួនក៏បានជិះម៉ូតូម្នាក់ឯង មកកន្លែងធ្វើឡានមួយស្ថិតនៅភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីមកយកទុយោខ្យល់ នៅពេលទៅដល់ទីនោះខ្លួនក៏បានឃើញឡានរបស់ខ្លួនខូចក៏បានសួរនាំជាងឡានថាឡានរបស់ខ្លួនខូចអ្វី ជាងឡានប្រាប់ថាជាស្ត្រីទន់ខ្សោយកំពុងមានផ្ទៃពោះ និងជាជនពិការរហូតដល់កាន់ឈើច្រត់ ស្របពេលនោះឈ្មោះ [redacted] លាង ក៏បានលួកដៃយកទូរស័ព្ទរបស់ខ្លួន នៅក្នុងកាបូបដែលនៅក្នុងនោះ មានទឹកប្រាក់នៅក្នុងស្រោមទូរស័ព្ទ ចំនួន ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក និងទឹកប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល នៅពេលនោះឈ្មោះ [redacted] សុផេង ក៏បានមកដល់វាយក្បាលខ្លួនបន្ថែមទៀត ដែលធ្វើឱ្យខ្លួន ធ្លាក់ឈាមតាមទ្វារមាសរហូតមិនឈប់ទើបខ្លួនដាក់ពាក្យបណ្តឹង។

សព្វថ្ងៃឈ្មោះ [redacted] សុផេង និងឈ្មោះ [redacted] លាង ស្នាក់នៅភូមិរលាំងបែង ឃុំយារអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ខ្លួនត្រឡប់មកផ្ទះវិញ ដោយឈ្មោះ [redacted] សុផេង ជាអ្នកមើលថែ។ មួយថ្ងៃក្រោយមក នៅវេលាម៉ោងប្រហែល០៤រសៀល ស្រាប់តែឈ្មោះ [redacted] សុផេង បានធ្វើសកម្មភាព យកដៃខ្ទប់មាត់ខ្លួន ហើយយកដៃឆ្វេង ស្រាតខោខ្លួនគាត់ និងស្រាតសារ៉ុងខ្លួន ហើយបានធ្វើសកម្មភាពចាប់រំលោភខ្លួនតែម្តង ដោយពេលនោះខ្លួនស្លៀកសារ៉ុង និងអាវដៃខ្លី ដោយមិនមានស្លៀកខោអាវក្នុងទេ។ គាត់ចាប់រំលោភខ្លួន ប្រហែលបីនាទីទើបចេញទឹកកាមក្នុងប្រដាប់ភេទរបស់ខ្លួន ហើយបានដកប្រដាប់ភេទគាត់ចេញវិញ ដោយយកកន្សែងមកជូតប្រដាប់ភេទគាត់ ប្រដាប់ភេទខ្លួន និងគ្រែពេទ្យ ហើយក៏បានយកទូរស័ព្ទថតប្រដាប់ភេទរបស់ខ្លួន។

មូលហេតុ ដែលខ្លួនមិនបានដាក់ពាក្យបណ្តឹង ដោយសារឈ្មោះ [redacted] សុផេង បានខ្ទប់មាត់ខ្លួនមិនឱ្យស្រែក ហើយតែដោយសារ តែ ដៃស្តាំ និងជើងឆ្វេង ខ្លួនសុទ្ធតែបាក់ទើបខ្លួនមិនអាចរើចេញពីសកម្មភាពរបស់គាត់បាន។ ពេលធ្វើសកម្មភាពរួច ឈ្មោះ [redacted] សុផេង បាននិយាយលួងលោមខ្លួន ថាកុំឱ្យប្តឹង គាត់នឹងទទួលខុសត្រូវចំពោះអំពើរបស់គាត់។ ដោយសារតែខ្លាចគាត់យករូបថតរបស់ខ្លួនទៅបង្ហោះ និងដោយសារគាត់ធានាថានឹងទទួលខុសត្រូវទើបខ្លួនមិនបានប្តឹងភ្លាមៗ។ លុះចេញពីមន្ទីរពេទ្យគាត់បានជូនខ្លួនទៅផ្ទះ និងជូនខ្លួនទៅពិនិត្យនៅមន្ទីរពេទ្យជាប្រចាំ។ ពេលគាត់រំលោភខ្លួនគាត់ក៏បានធ្វើឱ្យខ្លួនមានផ្ទៃពោះផងដែរ ប៉ុន្តែកូននោះត្រូវបានរលូត ដោយសារតែខ្លួនដួល។ លុះអំឡុងឆ្នាំ២០២២ ស្រាប់តែឈ្មោះ [redacted] សុផេង បានលួចយកខ្សែកមាស ០៣តម្លឹង ០៨ជី, ទឹកប្រាក់ ចំនួន ៧៥០០ (ប្រាំពីរប្រាំរយ) ដុល្លារអាមេរិក, រថយន្ត,ម៉ូតូ,ប័ណ្ណសម្គាល់រថយន្ត, ឯកសារទិញលក់រថយន្តនិងជួលរថយន្តទៅបាត់។ ខ្លួនក៏បានទំនាក់ទំនងទៅ



Scanned with
CamScanner

ឈ្មោះ [redacted] សុផេង ដើម្បីយករបស់របរមកសងខ្លួនវិញ ប៉ុន្តែឈ្មោះ [redacted] សុផេង មិនបានដោះស្រាយឡើយ។ សូមមេត្តាជួយរកយុត្តិធម៌ និងផ្តន្ទាទោសឈ្មោះ [redacted] សុផេង និងឈ្មោះ [redacted] ណាង ឱ្យបានត្រឹមត្រូវតាមច្បាប់។ សុំទាមទារប្រាក់ចំនួន ៨.៥៥០ (ប្រាំបីពាន់ប្រាំរយហាសិប) និងប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួនមកវិញរួមមានមាស០៣តម្លឹង ០៨ជី, ទឹកប្រាក់ ចំនួន ៧៥០០ (ប្រាំពីរប្រាំរយ) ដុល្លារអាមេរិក, រថយន្ត,ម៉ូតូ,ប័ណ្ណសម្គាល់រថយន្ត,ប័ណ្ណសម្គាល់ម៉ូតូ និងឯកសារទិញលក់រថយន្តនិងជួលរថយន្តទៅបាត់។ សុំទាមទារសំណងជម្ងឺចិត្តថ្លៃព្យាបាលចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។

៣.តាមការបញ្ជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន បានបញ្ជាក់ថា ខ្លួនបានកំពុងសម្រា កព្យាបាលនៅមន្ទីរពេទ្យខ្មែរសូវៀត ឈ្មោះ [redacted] សុផេង ជាមួយអ្នកមើលថែ ដោយឃើញថាមានសភាពស្ងាត់ល្អ បានរំលោភដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងខែកក្កដា ឆ្នាំ២០២១ ចំនុចនេះតុលាការយល់ឃើញថា មានតែការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់ឯងប៉ុណ្ណោះ ដោយពុំមានសាក្សី ឬរបាយការណ៍ព្រឹត្តហេតុអ្វីបញ្ជាក់ទាល់តែសោះ ដូច្នេះគម្បីតុលាការចាត់របៀបបង្វិលឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចបន្ថែមទៀតដូចខាងក្រោម:

១-ធ្វើដីកាបង្គាប់ឱ្យស្រាវជ្រាវរបាយការណ៍ព្រឹត្តហេតុ បានកើតហេតុនៅមន្ទីរពេទ្យខ្មែរ-សូវៀត ដែលដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះបានបញ្ជាក់ថា ខ្លួនបានដេកពេទ្យព្យាបាលរបួសនៅមន្ទីរពេទ្យ ខ្មែរ-សូវៀត កាលពីខែ កក្កដា ឆ្នាំ២០២១ ដូចការអះអាងរបស់ ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះដែរ ឬទេ?

២-កោះហៅសាក្សីជាម្តាយ ឪពុក រួមទាំងប្អូនឈ្មោះ [redacted] ចិន, ឈ្មោះ [redacted] រិទ្ធ ត្រូវជាឪពុក និងម្តាយឈ្មោះ [redacted] ហៀន ត្រូវជាម្តាយ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះមកសាកសួរនៅពេលដែលជនរងគ្រោះ មកសម្រាកព្យាបាលនៅមន្ទីរពេទ្យខ្មែរ សូវៀត និង ទំនាក់ទំនង រវាង ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះដូចម្តេច?

៣-ពិនិត្យភស្តុតាងថ្មី ដែលដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះបានដាក់មកតុលាការ ដែលភស្តុតាងទាំងនោះចៅក្រមស៊ើបសួរពុំទាន់ធ្វើការស្រាវជ្រាវ និងបំពេញកិច្ចឡើងវិញ រួមទាំង ជនជាប់ចោទឈ្មោះ [redacted] ណាង ត្រូវជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ [redacted] សុផេង ស្ថិតនៅក្នុងអង្គហេតុនេះដែលត្រូវ ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះអះអាងថាវាយមកលើខ្លួនផងដែរ ដោយបញ្ជាក់ និងស្វែងរកនូវព្រឹត្តហេតុ បានប្រព្រឹត្តលើជនរងគ្រោះ ព្រមទាំងស្វែងរកអត្តសញ្ញាណរបស់ឈ្មោះ [redacted] ណាង បន្ថែមទៀត ដោយហេតុថាមានអត្តសញ្ញាណ ពុំទាន់គ្រប់គ្រាន់នៅឡើយ។

បង្វិលសំណុំរឿងដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ ក្នុងការសម្រេចសេចក្តីនេះ គប្បីឱ្យចៅក្រមស៊ើបសួរ សាកសួរលើចំណុចខ្វះខាតខាងលើនេះ។

## ៥-ហេតុដូច្នេះសម្រេច

១-ចាត់របៀបបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៤២៨៨ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ទៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបំពេញកិច្ចស៊ើបសួរបន្ថែមដូចខាងក្រោម:

ក. ធ្វើដីកាចាត់ឱ្យស៊ើបសួរ នូវរបាយការណ៍ព្រឹត្តហេតុ បានកើតហេតុនៅក្នុងមន្ទីរពេទ្យខ្មែរ សូវៀត ដែល ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ ឈ្មោះ [redacted] សារឿន បានបញ្ជាក់ថា " បានសម្រាកព្យាបាលនៅមន្ទីរពេទ្យ ខ្មែរ សូវៀត កាលពីខែកក្កដា ឆ្នាំ២០២១ "។



Scanned with CamScanner

ខ.កោះហៅសាក្សី ជាម្ដាយឪពុក និងប្អូន របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]សារឿន មកសួរ។

គ. ពិនិត្យភស្តុតាងថ្មី ដែលដើមបណ្ដឹងរដ្ឋប្បវេណី និងជាជនរងគ្រោះបានដាក់មកតុលាការ ភស្តុតាងទាំងនោះ ចៅក្រមស៊ើបសួរពុំទាន់ធ្វើការស្រាវជ្រាវ និងបំពេញកិច្ចឡើងវិញ រួមទាំង ជនជាប់ចោទឈ្មោះ [redacted] ហាង ត្រូវជាប្រពន្ធ របស់ជនជាប់ចោទឈ្មោះ [redacted] សុផេង ស្ថិតនៅក្នុងអង្គហេតុនេះដែលត្រូវ ដើមបណ្ដឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ អះអាងថាវាយមកលើខ្លួនផងដែរ ដោយបញ្ជាក់ និងស្វែងរកនូវព្រឹត្តហេតុ បានប្រព្រឹត្តលើជនរងគ្រោះ ព្រមទាំងស្វែងរក អត្តសញ្ញាណរបស់ឈ្មោះ [redacted] ហាង បន្ថែមទៀត ដោយហេតុថាមានអត្តសញ្ញាណ ពុំទាន់គ្រប់គ្រាន់។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃពុធ ១៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជីសវនាការ

[redacted]